# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤១៦-៩៧

# អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ ភ្នំពេញ

**ផ្ញើមក**

**គ្រប់លោកព្រះរាជអាជ្ញាប្រចាំតុលាការខេត្ត ក្រុង និងយោធារ**

**សូមជ្រាប។**

**កម្មវត្ថុ:** នយោបាយបង្ក្រាបជនល្មើសឱ្យបានតឹងតែង និងប្រសិទ្ធិភាព ។

**យោង:** បញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ខ្ញុំសូមរំលឹកអស់លោកព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជាថា ក្នុងមួយរយៈពេលកន្លងមកនេះអំពើល្មើសព្រហ្មទណ្ឌគ្រប់បែបយ៉ាងមានភាពកើនឡើងប្រព្រឹត្តរបៀបអាណាធិបតេយ្យនៅគ្រប់ទិសទី ដែលជាអំពើទាក់ទាញអារម្មណ៍ បតិជាតិនិងអន្តរជាតិឱ្យយល់ឃើញថា អាជ្ញាធរមានសមត្ថកិច្ចរបស់យើងគ្មានមធ្យោបាយដើម្បីទប់ទល់និងបង្ក្រាបឱ្យមានប្រសិទ្ធិភាព ។

អំពើដែលមានប្រព្រឹត្តម្តងមកនោះ គឺអំពើប្លន់សម្លាប់ អំពើចាប់មនុស្សជម្រិតទារយកប្រាក់ អំពើពង្រត់មនុស្សដើម្បីលក់ឱ្យធ្វើស្រីបេស្យា។ល។ អំពើទាំងនេះអាចប្រព្រឹត្តទៅបានដោយសារជនល្មើសមានលទ្ធភាពប្រើប្រាស់អាវុធ ហើយអាវុធទាំងនេះជួនកាលជាអាវុធត្រឹមត្រូវតាមច្បាប់ មានលិខិតស្នាមត្រឹមត្រូវ ជួនកាលជាអាវុធគ្មានលិខិតស្នាមការប្រើប្រាស់ ឬទិសដៅប្រើប្រាស់មិនត្រឹមត្រូវតាមច្បាប់ ។ ប្រភពអាវុធគ្មានច្បាប់គេឃើញស្ថិតនៅកន្លែងទីផ្សារទឹកថ្លា ដែលគ្រប់ជនល្មើសអាចទៅរកទិញបាន ជនល្មើសជាឈ្មួញអាចទិញ អាចលក់ និងអាចរក្សាជាសន្និធិ ស្តុកបានដោយគ្មានបារម្ភថាល្មើសនិងច្បាប់ ហើយមានទោសនោះសោះ ។ ម្យ៉ាងទៀតអាវុធដែលខុសច្បាប់ជនល្មើសអាចស្វែងរកជនល្មើសក្លែងលិខិតបន្ថែមទៀត ដើម្បីមានលិខិតបញ្ជាក់អំពីភាពស្របច្បាប់ចំពោះមុខអាជ្ញាធរដែកឆេរ ឬចំពោះឈ្មួញបន្ត ឬអ្នកទិញប្រើប្រាស់បន្តបានដោយស្រួល ។ ចំណែកសម្បត្តិទ្រព្យបានមកពីអំពើល្មើសក៏ដូច្នេះដែរ ឧទាហរណ៍ ម៉ូតូ ឬរថយន្ត ដែលជាវត្ថុល្មើស ជនល្មើសអាចធ្វើលិខិតប័ណ្ណសម្គាល់យានយន្តក្លែងបានយ៉ាងឆាប់រហ័ស អាចរកឈ្មួញទិញ ឬរដូបានដោយស្រួល ដែលជាកត្តាជម្រុញបទលួច ប្លន់ ឱ្យកាន់តែរីកដុះដាលថែមទៀត ។

ខ្ញុំសង្កេតឃើញថា អំពើជួញដូរអាវុធ និងក្លែងលិខិតខាងលើ មិនសូវឃើញអយ្យការចោទប្រកាន់ជាបទល្មើស ហើយសុំឱ្យតុលាការកាត់ទោសសោះ ដែលជាភាពមួយឱ្យយល់ថាអំពើទាំងនេះមិនខុសនិងច្បាប់ទេ ។ ប៉ុន្តែផ្ទុយទៅវិញអំពើទាំងនេះជាអំពើរក្សាអាវុធ កាន់កាប់អាវុធ ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៤នៃច្បាប់ព្រហ្មទណ្ឌ និងអំពើក្លែងលិខិត ប័ណ្ណសម្គាល់យានយន្ត ជាអំពើក្លែងលិខិតសាធារណៈចែងក្នុងមាត្រា ៤៩ច្បាប់ព្រហ្មទណ្ឌ បន្ថែមទៅនឹងអំពើខាងលើ ខ្ញុំសូមរំលឹកថាមានអំពើត្រួតពិនិត្យតាមដងផ្លូវជាតិសាធារណៈConitrole ជជុះ ក៏ជាបទល្មើសព្រហ្មទណ្ឌដែរ ព្រោះបើអំពើនេះប្រព្រឹត្តដោយក្រុមត្រួតពិនិត្យមិនត្រឹមត្រូវជាអំពើប្លន់មាត្រា ៣៤ ច្បាប់ព្រហ្មទណ្ឌ បើប្រព្រឹត្តដោយក្រុមControle ត្រឹមត្រូវទៅលើកំហុសរបស់អ្នកដឹកជញ្ជូនជាអំពើទារសំណូកចែងក្នុងមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌ ដូច្នេះត្រូវតែអយ្យការចាត់ការឱ្យមានប្រសិទ្ធិភាពទៅអនាគត ។

ខ្ញុំសូមរំលឹកថានៅពេលថ្មីៗនេះ សម្តេចនាយករដ្ឋមន្ត្រីទី២ បានមានវិធានការណ៍ចាត់ការរៀបចំឱ្យមានរបៀបរៀបរយឡើងវិញ ដោយសុំឱ្យផ្តន្ទាទោសជនល្មើសបង្កើតបទល្មើសអាណាធិបតេយ្យទាំងនោះឱ្យបានតឹងរឹងដើម្បីផ្តល់សុវត្ថិភាពជូនភ្ញៀវបេសកជនអន្តរជាតិ ជនអន្តោប្រវេសន៍ វិនិយោគទុន អនិកជន ភ្ញៀវទេសចរណ៍ និងប្រជាជនខ្មែរឱ្យបានពេញលេញ ហើយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏មានសេចក្តីណែនាំសូមឱ្យ

តុលាការគ្រប់ជាន់ថ្នាក់មានវិធានការណ៍ផ្តន្ទាទោសជនល្មើសឱ្យបានតឹងរឹងដែរ ដូចលោកបានរៀបរាប់ក្នុងលិខិតចត ចម្លងជូនភ្ជាប់មកជាមួយនេះ ។

ដូច្នេះខ្ញុំសូមលោកព្រះរាជអាជ្ញប្រចាំតុលាការគ្រប់ខេត្ត-ក្រុង យកចិត្តទុកដាក់អនុវត្តច្បាប់ឱ្យបានហ្មត់ចត់ ចោទប្រកាន់ និងជូនខ្លួនជនល្មើសទៅតុលាការឱ្យបានគ្រប់បទល្មើស និងសន្និដ្ឋានសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសឱ្យ បានតឹងតែងដូចចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រីនេះតទៅ

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៧

**អគ្គរដ្ឋអាជ្ញា**

**ហាច់រ៉ូ រ៉ាកេន**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-តុលាការកំពូល និងមហាអយ្យការប្រចាំតុលាការកំពូល
-សាលាឧទ្ធរណ៍
-តុលាការខេត្ត.ក្រុង និងយោធា
-ដើម្បីជ្រាបជាព័ត៌មាន